**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ៣៦០៦ មស.សជ៣

# សេចក្តីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់បេក្ខជន ដែលបានបំពេញសំណុំបែបបទសុំសិទ្ធិប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នទាំង៧ ឱ្យបានជ្រាបថា គណៈកម្មការរៀបចំការប្រឡងនឹងធ្វើការបិតផ្សាយបញ្ជីឈ្មោះបេក្ខជន ដែលបានបំពេញនូវលក្ខខណ្ឌសមស្របឱ្យចូលរួមប្រឡងក្របខណ្ឌសម្រាប់ឆ្នាំ២០១៧នេះ តាមការកំណត់ដូចខាងក្រោម៖

**១-** បញ្ជីរាយនាមបេក្ខជន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចូលរួមប្រឡងមានបិតផ្សាយនៅក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល *ចាប់ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ តទៅ។*

*បេក្ខជន បេក្ខនារី មានសិទ្ធិតវ៉ាមកអនុគណៈកម្មការទទួលពាក្យ និងរៀបចំឯកសារ នៅក្រសួងមុខងារសាធារណៈ ក្នុងករណីមិនមានឈ្មោះប្រឡង ឬបញ្ហាផ្សេងៗ ត្រឹមថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១៧៖០០ ។*

**២-សម័យប្រឡង៖ នៅថ្ងៃអាទិត្យ ទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧**

**៣-មណ្ឌលប្រឡង៖**

**ក. វិទ្យាល័យចាក់អង្រែ សម្រាប់ក្រសួង ស្ថាប័នដូចខាងក្រោម៖**

- ក្រសួងមុខងារសាធារណៈ
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងទេសចរណ៍
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**ខ. វិទ្យាល័យសន្ធរម៉ុក សម្រាប់ក្រសួង ដូចខាងក្រោម៖**

- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**៤-ពេលវេលាប្រឡង៖**

ក. **ម៉ោង ០៦:០០នាទី៖** គណៈកម្មការរៀបចំការប្រឡង អនុគណៈកម្មការនានា និងបេក្ខជនត្រូវមកដល់មណ្ឌលប្រឡង

ខ. **ម៉ោង ០៦:៣០នាទី ដល់ ម៉ោង ០៦:៥០នាទី៖** អនុរក្សហៅឈ្មោះបេក្ខជនចូលបន្ទប់ ត្រួតពិនិត្យវត្តមាន ប្រកាសបទបញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន



ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

គ. ម៉ោងទី១ ចាប់ពីម៉ោង ០៧:០០នាទី ដល់ ម៉ោង ៩:០០នាទី

ឃ.ម៉ោងទី២ ចាប់ពីម៉ោង ០៩:៣០នាទី ដល់ ម៉ោង ១១:៣០នាទី

**៥-វិញ្ញាសាប្រឡងសម្រាប់ក្រសួង ស្ថាប័ន ត្រូវបានកំណត់ដូចខាងក្រោម៖**

**ក. ក្រសួងមុខងារសាធារណៈ**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក**

**ខ. ក្រសួងពាណិជ្ជកម្ម វិញ្ញាសា**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**
- ម៉ោងទី២៖ វិញ្ញាសាជំនាញ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទ ក្របខណ្ឌ **ក** និង **ខ** កំណត់ដូចខាងក្រោម៖
  ១. គីមីចំណីអាហារ
  ២. គណនេយ្យ ហិរញ្ញវត្ថុ សេដ្ឋកិច្ចពាណិជ្ជកម្ម គ្រប់គ្រងទូទៅ
  ៣. នីតិសាស្ត្រ ច្បាប់ពាណិជ្ជកម្ម
  ៤. ព័ត៌មានវិទ្យា

**គ.ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក និង ខ** ចំពោះបេក្ខជនដែលជ្រើសរើសជំនាញ គ្រប់គ្រង, គណនេយ្យ, ហិរញ្ញវត្ថុ, ធនាគារ, អង់គ្លេស, នីតិសាស្ត្រ, និង រដ្ឋបាលសាធារណៈ
- ម៉ោងទី២៖ វិញ្ញាសាជំនាញ ព័ត៌មានវិទ្យា រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក និង ខ** ចំពោះបេក្ខជនដែលជ្រើសរើសជំនាញ ព័ត៌មានវិទ្យា

**គ.១ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក**
- ម៉ោងទី២៖ វិញ្ញាសាជំនាញទូរគមនាគមន៍និងបណ្តាញ អប់រំពីចម្ងាយ ឬបច្ចេកវិទ្យាចល័ត រយៈពេល ០២ម៉ោង ចំពោះបេក្ខជនជ្រើសរើសជំនាញទូរគមនាគមន៍និងបណ្តាញ អប់រំពីចម្ងាយ ឬបច្ចេកវិទ្យាចល័ត សម្រាប់ប្រភេទក្របខណ្ឌ **ក**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ ចំពោះបេក្ខជនដែលជ្រើសរើសជំនាញគណនេយ្យ ហិរញ្ញវត្ថុ ឬធនាគារ រយៈពេល០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក**

**ឃ. ក្រសួងធនធានទឹកនិងឧតុនិយម**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក**

**ង. ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**

**ច. ក្រសួងទេសចរណ៍**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យទេសចរណ៍ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេស រយៈពេល ០១ម៉ោង៖៣០នាទី សម្រាប់ប្រភេទក្របខណ្ឌ **ក**

**ឆ. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**

**៦-** ចំពោះ**ប្លង់មណ្ឌលប្រឡង លេខបន្ទប់ និងលេខតុ** របស់បេក្ខជន បេក្ខនារីនឹងធ្វើការបិតផ្សាយនៅវិទ្យាល័យបាក់ទូក និងវិទ្យាល័យសន្ធរម៉ុក *នាថ្ងៃសៅរ៍ ទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោ ០៩៖០០នាទីព្រឹក*

**៧-** អង្គភាពថ្នាក់កណ្តាល ឬមន្ទីររាជធានី ខេត្ត ដែលគ្មានបេក្ខជនដាក់ពាក្យសុំសិទ្ធិប្រឡង គណៈកម្មការរៀបចំការប្រឡង និងធ្វើនិយ័តចំនួនក្របខណ្ឌ ទៅអង្គភាពផ្សេងទៀតដែលមានតម្រូវការចាំបាច់ តាមសំណើររបស់សាមីក្រសួងស្ថាប័ន។

អាស្រ័យហេតុនេះ សូមបេក្ខជន បេក្ខនារី ដែលមានឈ្មោះចូលរួមប្រឡង ត្រូវយកមកជាមួយនូវឯកសារដូចជាសលាកប័ត្រឯកត្តជន អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណសំគាល់ខ្លួនសិស្ស និស្សិត ជាដើម។

*បញ្ជាក់៖ គណៈកម្មការរៀបចំការប្រឡង មានសិទ្ធិកែប្រែសេចក្តីជូនដំណឹងនេះ ក្នុងករណីចាំបាច់៕*

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៧

**រដ្ឋលេខាធិការនិងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**យូ ស៊ុនឡុង**

-ឯកសារ កាលប្បវត្តិ